ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០២២

នៅក្នុងខែកញ្ញានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារតាមដានការអនុវត្តច្បាប់**

-បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាគណៈកម្មការទី៥ ព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខអាជ្ញាធរមានសមត្ថកិច្ច និងពិនិត្យស្ថានភាពចេញ-ចូលរបស់ភ្ញៀវជាតិ-អន្តរជាតិ និងប្រជាពលរដ្ឋ នៅច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន ខេត្តតាកែវ និងបានជួបសំណេះសំណាលជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅស្រុកពញាឮ ខេត្តកណ្តាល។

**២- មុខងារតំណាង**

-បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី** អញ្ជើញចែកអំណោយ ជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី អាជ្ញាធរ កងកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាល និងប្រជាពលរដ្ឋ ព្រមទាំងប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធមហាឧបាសក **គង់ ខាត់** និងមាតា បិតា ញាតិកាទាំងប្រាំពីរសន្តាន ដែលបានចែកឋានទៅកាន់លោកខាងមុខ នៅស្រុកបាធាយ និងស្រុកកោះសូទិន ខេត្តកំពង់ចាម

-បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី** និង **ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** អញ្ជើញគោរពវិញ្ញាណក្ខន្ធ ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ញឹម តេង** ដែលត្រូវជាម្តាយក្មេកលោកជំទាវកិត្តិសង្គហ-



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oumsarith_sgsenate@gmail.com, oumsarith_sgsenate@yahoo.com

បណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅរាជធានីភ្នំពេញ

- បានរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមពិធីកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌ តាមប្រពៃណី និងគន្លងព្រះពុទ្ធសាសនា តាមវត្តអារាមនានា នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុង

- បានរៀបចំបែបបទ ផ្ដល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ អាណត្តិទី៥ ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ព្រមទាំងចូលរួមពិធីគោរពវិញ្ញាណក្ខន្ធ នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តកណ្ដាល ខេត្តតាកែវ ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្ត-កំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀងចំនួន៩៩លើក

- បានធ្វើបទបង្ហាញស្ដីពី បទពិសោធន៍ និងតួនាទីរបស់ព្រឹទ្ធសភា និងទស្សនវិស័យទាក់ទងនឹងឱកាសសម្រាប់ការចូលរួមរបស់សាធារណជន និងគណនេយ្យភាពក្នុងអំឡុងវដ្ដថវិកា

- ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីពិនិត្យវឌ្ឍនភាពនៃការកសាងសមត្ថភាពសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានជាប់ឆ្នោតអាណត្តិទី៥ និងកិច្ចការផ្សេងៗ ព្រមទាំងបានឧបត្ថម្ភសៀវភៅសរសេរចំនួន៦,២០០ក្បាល ដើម្បីចែកជូនសិស្សានុសិស្សដែលកំពុងខ្វះខាតក្នុងមូលដ្ឋានក្នុងថ្ងៃបើកបវេសនកាលឆ្នាំសិក្សាថ្មី នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសាធារណរដ្ឋបារាំង ចុះទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋក្រីក្រ ឥតយកកម្រៃ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- បានទទួលពាក្យបណ្ដឹងចំនួន០១ករណី បញ្ជូនពាក្យបណ្ដឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន០៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធ

ចំនួន០៣ករណី កំពុងពិនិត្យសិក្សាចំនួន០៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៣ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន០៤ករណី

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភាចំនួន១២នាក់

-បានរៀបចំចាត់ចែងជូនថ្នាក់ដឹកនាំ និងគណៈប្រតិភូព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០៩លើក ព្រមទាំងបានរៀបចំ និងផ្ញើសាររំលែកទុក្ខជូនគ្រួសារសពមន្ត្រីជាន់ខ្ពស់ចំនួន០៨លើក

-បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីប្រចាំខែកញ្ញា ឆ្នាំ២០២២ ចំនួន៨០០ក្បាល។

## ៣- មុខងារសហប្រតិបត្តិការអន្តរជាតិ

-បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជូនសារតាំង សម្តែងការគួរសម និងពិភាក្សាការងារជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី** ជាមួយឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពទើបតែងតាំងថ្មីនៃសាធារណរដ្ឋបេឡារុស, ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពទើបតែងតាំងថ្មីនៃសាធារណរដ្ឋក្វាតេម៉ាឡា, ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពទើបតែងតាំងថ្មីនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់, ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពទើបតែងតាំងថ្មីនៃសាធារណរដ្ឋតួកគី និងគណៈប្រតិភូគណៈកម្មការស៊ើបអង្កេតអំពើពុករលួយការប្រព្រឹត្តខុស និងពង្រឹងអភិបាលកិច្ចល្អនៃព្រឹទ្ធសភា ព្រះរាជាណាចក្រថៃឡង់ដ៍

-បានរៀបចំចាត់ចែងជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី** និង**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា ប្រធានស្តីទីព្រឹទ្ធសភា** ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ**ព្រះមហាក្សត្រីយ៍ អេលីហ្សាបេតទី២** នៃចក្រភពអង់គ្លេស នៅស្ថានឯកអគ្គរាជទូតនៃចក្រភពអង់គ្លេស ប្រចាំព្រះរាជាណាចក្រកម្ពុជា

-បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ការងារជូនសមាជិកព្រឹទ្ធសភា ជាមួយគណៈប្រតិភូគណៈកម្មការស៊ើបអង្កេតអំពើពុករលួយការប្រព្រឹត្តខុស និងពង្រឹងអភិបាលកិច្ចល្អនៃព្រឹទ្ធសភា ព្រះរាជាណាចក្រថៃឡង់ដ៍

-បានសហការជាមួយរដ្ឋសភារៀបចំសិក្ខាសាលាស្តីពី ស្ថិយភាពសេដ្ឋកិច្ចរបស់ស្ត្រីនៅតំបន់ជនបទ ការចរចា និងសន្ទានកម្ម នៅក្នុងមជ្ឈដ្ឋានសភាប្រើភាសាបារាំង(APF)

-បានរៀបចំចាត់ចែងជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានា តាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់ រួមមានៈ កិច្ចប្រជុំគណៈកម្មការត្រៀមរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤៣, កិច្ចប្រជុំជាមួយរដ្ឋសភាកម្ពុជា ដឹកនាំដោយ

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ រដ្ឋសភា ជាមួយសមភាគីសភាប្រជាជនចិនទូទាំងប្រទេស ដឹកនាំដោយឯកឧត្តម **វ៉ាង ជិន** អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រជាជនចិនទូទាំងប្រទេស, កិច្ចប្រជុំពិគ្រោះយោបល់របស់គណៈកម្មាធិការស្ត្រីវ៉ាយប៉ា (WAIPA) និងស្តាប់បទបង្ហាញរបស់លោកជំទាវ **ង្វៀន ទួង វ៉ាន់** អគ្គលេខាធិការអន្តរសភាអាស៊ាន(AIPA) ប្រចាំទីក្រុងហ្សាកាតា សាធារណរដ្ឋឥណ្ឌូនេស៊ី អំពីទីតិវិធី និងរបៀបរបបការងាររៀបចំមហាសន្និបាតអាយប៉ាលើកទី៤៣ ព្រមទាំងកិច្ចប្រជុំពាក់ព័ន្ធ នៅវិមានរដ្ឋសភា ព្រមទាំងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៤ នៅខេត្តសៀមរាប

- ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យអគ្គទីប្រឹក្សាស្ថានទូតជប៉ុនចូលជួបពិភាក្សាការងារ និងអញ្ជើញចូលរួមមហាសន្និបាតសមាគមអគ្គលេខាធិការសភាប្រេីភាសាបារាំង(ASGPF) នៅព្រះរាជាណាចក្រម៉ារ៉ុក

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតចិន, ស្ថានទូតសិង្ហបុរី,ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ដៃគូភាគីចិន, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការមូលនិធិអាស៊ី, អង្គការតម្លាភាពកម្ពុជា (TI Cambodia), រាជបណ្ឌិតសភាកម្ពុជា, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា(CDC), សាលាភូមិន្ទរដ្ឋបាល, មជ្ឈមណ្ឌលសភាអាស៊ី(PCA), វិទ្យាស្ថានSunrise, វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានGreatX Center, វិទ្យាស្ថានSalaCyber, ភ្នាក់ងារសង្គមព័ត៌មានជាតិ(NIA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៤- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានរៀបចំពិធីសម្ពោធស្លាកសមិទ្ធផលលើការជួសជុលអគារក្រហម និងបណ្ណាល័យព្រឹទ្ធសភា ដែលជាជំនួយរបស់ស្ថានទូតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា

- បានរៀបចំកម្មវិធីសប្បុរសធម៌បរិច្ចាគឈាម សហការជាមួយមជ្ឈមណ្ឌលជាតិផ្តល់ឈាម នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

- បានប្រជុំគម្រោងបែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២៣ ក្នុងវចនាសម្ព័ន្ធនយោបាយ វចនាសម្ព័ន្ធរដ្ឋបាល លទ្ធកម្ម និងការអភិវឌ្ឍន៍

- បានប្រជុំពិនិត្យរបាយការណ៍សមិទ្ធកម្មត្រីមាសទី២ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងកម្រិតបច្ចេកទេស

## ៤.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានបើកប្រាក់បៀវត្សប្រចាំខែកញ្ញា ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានតាមដានគោលការណ៍ និងព័ត៌មានថ្មីទាក់ទងនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗ និងកំណត់បង្ហាញចំនួន២២ច្បាប់

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្រប នឹងដំណាក់កាលថ្មី

- បានបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសចំនួន០៤វគ្គ មានសិក្ខាកាមចូលរួមចំនួន ៧០នាក់ និងក្រៅប្រទេសចំនួន០៤វគ្គ មានសិក្ខាកាមចូលរួមចំនួន០៥នាក់ ព្រមទាំងសិក្ខាសាលាក្នុងប្រទេសចំនួន០១លើក មានសិក្ខាកាមចូលរួមចំនួន៧០នាក់

- បានរៀបចំដំណើរទស្សនកិច្ចសិក្សារបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញសិក្សាឈ្វេងយល់ពីភូមិគំរូមិត្តភាពកម្ពុជា-ចិន នៅស្រុកបាទី ខេត្តតាកែវ

- បានរៀបចំពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី ជំនាញការពារថ្នាក់ដឹកនាំ របៀបប្រើប្រាស់ខ្លោងទ្វារសុវត្ថិភាព និងបច្ចេកទេសម៉ាស៊ីន X-Ray, វគ្គការប្រាស្រ័យឆ្លើយឆ្លងគោលនយោបាយសាធារណៈ តាមប្រព័ន្ធវីដេអូ(Zoom)

- បានធ្វើរបាយការណ៍វាយតម្លៃការធ្វើបទបង្ហាញរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៃវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងធនធានមនុស្សចំនួន៣៨អង្គភាព

- បានទទួលលិខិតចូលចំនួន៤៤៨ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៣៦ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន០៨លើក

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានជួសជុលកែលម្អះ ដំបូលសាលប្រជុំខាងជើង សាលពិសេស៣ និងអគារបណ្ណាល័យ,

សំយ៉ាបសាលពិសេស១ និងសាលពិសេសក្រោម, សំយ៉ាបពិដានអគារមូលនិធិខ្មែរអភិវឌ្ឍន៍ និងនាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ, ប្រព័ន្ធជណ្តើរយន្តនៅអគារសមាជិកព្រឹទ្ធសភា, ប្រព័ន្ធអគ្គិសនី, លាបថ្នាំអគារជប៉ុន និងប្តូរកម្រាលព្រំនៅអគារ D E F

-បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក, ត្រួតពិនិត្យសត្វកណ្តៀរ, ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, បិទលេខកូដសម្ភារសារពើភណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣១៤គ្រឿង/លើក

-បានបោកអ៊ុតកម្រាលតុ វាំងនន ជួសជុលតុប្រជុំ និងកៅអី នៅតាមសាលប្រជុំ និងអង្គភាពនានាចំនួន១៩៥ឈុត/គ្រឿង

-បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន៤០លើក

-បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែកញ្ញា និងប្រចាំនព្វមាស ឆ្នាំ២០២២ ទូលថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា និងប្រចាំនព្វមាស ឆ្នាំ២០២២ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា

-បានធ្វើរបាយការណ៍ស្តីពី ការពិនិត្យ និងតាមដានការអនុវត្តផែនការប្រតិបត្តិរបស់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានទាំង៥ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២។

### ៤.២-ការងារសេវាច្បាប់៖

-បានទទួលសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ ពីរាជរដ្ឋាភិបាល

-បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន២៥៥ច្បាប់

-បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន០៣ច្បាប់

-បន្តចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ។

## ៤.៣-ការងារស្រាវជ្រាវ៖

-កំពុងសិក្សាស្រាវជ្រាវលើសេចក្ដីព្រាងច្បាប់ចំនួន០១ច្បាប់

- បានតាមដាន និងចងក្រងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា (ឆ្នាំ២០២១-២០៣៥)៖ ការរៀបចំក្របខណ្ឌស្ថាប័ន យន្តការសម្របសម្រួល ការតាមដាន និងវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយ

- កំពុងសិក្សាស្រាវជ្រាវ និងចងក្រង និងផលិតឯកសារលើប្រធានបទចំនួន១៦ប្រធានបទ

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៨៨អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែកញ្ញា ឆ្នាំ២០២២ ចំនួន០៤ច្បាប់។

## ៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចចំនួន០២លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេក-វិទ្យាព័ត៌មានចំនួន១៣៦គ្រឿង។ បានបញ្ចូលព័ត៌មានស្ដីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាចំនួន ១១០ប្រធានបទ

- បានបន្តបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ និងIpad ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៩គ្រឿង

- បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន១០៣ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ អ៊ុតក្របសៀវភៅចំនួន១០០ក្បាល

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៣៧លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១៧លើក

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Chanel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន ១,២៧៨ប្រធានបទ

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង

ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន។

**៤.៥-ការងារពិធីការ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២៦លើក
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន០៥ច្បាប់
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែកញ្ញា ឆ្នាំ២០២២ ចំនួន០១ច្បាប់
- បានកសាងជំនួយស្មារតី និងបកប្រែឯកសារនានាជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន១៤ច្បាប់។

**៤.៦-ការងារអគ្គាធិការដ្ឋាន៖**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា ឆ្នាំ២០២២ ចំនួន១៩លើក
- បានជួបប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើរបាយការណ៍ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារនៃអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា
- បានចុះត្រួតពិនិត្យជាក់ស្តែងតាមនាយកដ្ឋាន ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃចំនួន២២លើក ប្រចាំសប្តាហ៍ចំនួន០៤លើក និងប្រចាំខែកញ្ញា ឆ្នាំ២០២២
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែកញ្ញា ឆ្នាំ២០២២។

II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៩៩ច្បាប់

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៨ច្បាប់ ស្មើនឹង៣៩នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៣ច្បាប់ ស្មើនឹង០៣នាក់

- បានសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២១០លីត្រ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២៥២លើក

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៦៦សំណើ

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៣០លើក មានអ្នកចូលរួមចំនួន១,៣៧៣នាក់

- បានថតចម្លងឯកសារចំនួន១,៩៤៩ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន២១៣ក្បាល អស់ក្រដាសចំនួន៤៧,៨២៩សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន១៨៨លើក ស្មើនឹង៣៧៣នាក់

- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាពចំនួន១០លើក

- បានផលិត និងផ្សព្វផ្សាយវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន០៨លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន១៤៤លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១៦លើក។

## II-ទិសដៅការងារខែតុលា ឆ្នាំ២០២២

*+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ*

*+បន្តប្រឈមការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន*

*+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ*

*+លើកកម្ពស់សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេកវិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព*

***-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ***

*+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា។*

### ១- មុខងារនីតិកម្ម

*-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងបើកសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៩ នីតិកាលទី៤ មានរបៀបវារៈដូចខាងក្រោម៖*

*+សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីបួនស្តីពី វិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។*

### ២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

*-ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា*

*-ត្រៀមរៀបចំពិធីជំនួបពិភាក្សាការងារជូនគណៈកម្មការទី១ព្រឹទ្ធសភា ជាមួយលេខាធិការដ្ឋានគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នៃក្រសួងមហាផ្ទៃ, តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងតំណាង*

ក្រសួងបរិស្ថាន

-ត្រៀមរៀបចំពិធីជំនួបពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការស្តារនីតិសម្បទាឡើងវិញ។

### ៣- មុខងារតំណាង

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទង ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន និងអាជ្ញាធរដែនដី ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមរៀបចំពិធីសំណេះសំណាលជាមួយនិវត្តជន និងមន្ត្រីរាជការវ័យចំណាស់នៃ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ០១ តុលា

-ត្រៀមរៀបចំជូនសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២, ទី៤, ទី៥ និងទី៦ ចុះជួបសំណេះ-សំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខេត្តឧត្តរមានជ័យ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប

-ត្រៀមរៀបចំជូនក្រុមសមាជិកាព្រឹទ្ធសភា ចុះជួបសំណេះសំណាលជាមួយក្រុមមាជិកាឃុំ-សង្កាត់នៅខេត្តសៀមរាប

-ត្រៀមទទួលដំណើរទស្សនកិច្ចសិក្សារបស់សាស្ត្រាចារ្យ និងនិស្សិតពូកែ មកពីសាកលវិទ្យា-ល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យជាតិសំខាន់ៗ រួមមានៈ ពិធីបុណ្យគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ, ព្រះរាជកម្មវិធី "១០០ព្រះវស្សានៃព្រះបិតាឯករាជ្យជាតិ", បុណ្យកឋិន, ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិ និងពិធីបុណ្យឯករាជ្យជាតិ។

### ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម (សប្តាហ៍ទី០៤ ខែតុលា ឆ្នាំ២០២២)

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំក្នុងពិធីជំនួបជាមួយអគ្គទូតនានានៃប្រទេសជាមិត្ត

-ត្រៀមរៀបចំជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ក្នុងពិធីជំនួបជាមួយ នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋគុយបា

-ត្រៀមចូលរួមកិច្ចប្រជុំកំពូលប្រធានសភា លើកទី៨ នៃក្រុមប្រទេស G20 នៅសាធារណរដ្ឋឥណ្ឌូនេស៊ី (ថ្ងៃទី០៦-០៧ ខែតុលា ឆ្នាំ២០២២), កិច្ចប្រជុំ AIPA-ASEAN Interface (ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២) នៅព្រះរាជាណាចក្រកម្ពុជា, មហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញក្រុមសីលធម៌សមាជិកសភា និងកិច្ចប្រជុំការងារសើរើលក្ខន្តិកៈសភាប្រើភាសាបារាំង(APF) នៅសាធារណរដ្ឋបារាំង និងទស្សនកិច្ចការងារនៅសភាសហព័ន្ធវ៉ាលឡូនី-ព្រុចសែល ព្រះរាជាណាចក្របែលហ្ស៊ិក (ថ្ងៃទី០១-១៤ ខែវិច្ឆិកា ឆ្នាំ២០២២), កិច្ចប្រជុំ(APPF) នៅព្រះរាជាណាចក្រថៃឡង់ដ៍, មហាសន្និបាតសហភាពអន្តរសភាលើកទី១៤៥ (IPU145), មហាសន្និបាត(AIPA), (APF), (IPU) និងកិច្ចប្រជុំពាក់ព័ន្ធ

-ត្រៀមចូលរួមកម្មវិធីបណ្តុះបណ្តាលកិច្ចការសភាតំបន់នៅខេត្តសៀមរាប និងកិច្ចប្រជុំក្រុមប្រឹក្សាតំបន់ PCA (ថ្ងៃទី១៨-២១ ខែតុលា ឆ្នាំ២០២២)

-ត្រៀមរៀបចំមហាសន្និបាតអាយប៉ាលើកទី៤៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCA) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី

-ជំរុញកម្មវិធីបណ្តុះបណ្តាលមន្ត្រីក្នុង និងក្រៅប្រទេស តាមកម្មវិធីសហប្រតិបត្តិការជាមួយភាគីជាមិត្ត និងដៃគូផ្សេងៗទៀត

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍន៍ស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

-ត្រៀមរៀបចំរបាយការណ៍បែងចែកការប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២៣ សម្រាប់របនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បន្តតាមដានជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គម្រោងស្នើកសាងអគារថ្មី១ខ្នង និងការស្វែងរកជំនួយពីរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ និងការស្នើសុំឥណទានបន្ថែមពីរាជរដ្ឋាភិបាល

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែតុលា ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ឱ្យបានទាន់ពេលវេលា

-ត្រៀមរៀបចំបែបបទដំឡើងប្រាក់បំណាច់មុខងារដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០២៣ និងត្រៀមឧបត្ថម្ភបន្ថែមប្រាក់សោធននិវត្តន៍ដល់អតីតនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តវិចារណកម្មថវិកាៈ សន្សំសំចៃ និងអាទិភាពចំពោះតែការងារចាំបាច់បន្ទាន់ និងប្រញាប់បំផុតៈ

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ចាប់ផ្ដើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-ត្រៀមរៀបចំឯកសារគោលស្ដីពី តួនាទី ភារកិច្ច របស់នាយកដ្ឋាន និងអង្គភាពចំណុះអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារពិពណ៌នាការងារ និងបញ្ជាក់ពីសមត្ថភាពធ្វើការងាររបស់មន្ត្រីរាជការ

-ត្រៀមរៀបចំគោលការណ៍ គោលនយោបាយថ្មី ស្របតាមដំណើរការងារ និងស្ថានភាពជាក់ស្ដែងចំនួន០៣គឺៈ

១-គោលការណ៍ស្ដីពី ការផ្ដល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការមានស្នាដៃឆ្នើម

២-គោលការណ៍ស្ដីពី ការវាយតម្លៃការបំពេញការងាររបស់មន្ត្រីរាជការ

៣-គោលនយោបាយស្ដីពី ការគ្រប់គ្រងធនធានមនុស្ស

-ត្រៀមធ្វើជំរឿនសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តម្រូវការ និងការប្រឈម

-ធ្វើបច្ចុប្បន្នភាពផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរយៈពេល១០ឆ្នាំ (២០២២-២០៣០) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ធ្វើសម្រង់តម្រូវការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រីរាជការប្រចាំឆ្នាំ២០២៣

-កសាងផែនការបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឆ្នាំ២០២៣

-ត្រៀមបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមវគ្គបណ្តុះបណ្តាលកិច្ចការសភា នៅសាលារដ្ឋបាលជាតិបារាំង, វគ្គសូចនាករ សមិទ្ធកម្មគន្លឹះ(KPI) នៅប្រទេសឥណ្ឌា និងវគ្គកិច្ចការសភា នៅប្រទេសកាណាដា

-ធ្វើបច្ចុប្បន្នភាពជំរឿនស្ថិតិសមត្ថភាពជំនាញរបស់មន្ត្រីរាជការប្រចាំឆ្នាំ និងធ្វើជំរឿនមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ឆ្នាំ២០២២

-ត្រៀមធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា លើកកម្ពស់សមត្ថភាពដឹកនាំ និងគ្រប់គ្រងគ្រប់កម្រិត គ្រប់វិស័យ ពង្រឹងពង្រីកសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងសាធារណៈ

-សិក្សាគម្រោង និងប្លង់សាងសង់សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មី និងប្លង់សាងសង់របងថ្មីខាងមុខព្រឹទ្ធសភា

-បន្តការងារជួសជុលថែទាំអគារ ការលាបថ្នាំអគារជប៉ុនទី១ ទី២, ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា, អគារបណ្ណាល័យ, គូសគំនូសចរាចរចំណតយានយន្ត និងជួសជុលផ្លាស់ប្តូរគ្រឿងបរិក្ខារផ្សេងៗនៅតាមអគារ

-កែលម្អបរិស្ថាន និងអនុវត្តការងារជួសជុលផ្សេងៗក្នុងករណីចាំបាច់ ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងវិន័យការងារ

-ត្រៀមរៀបចំផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥របស់ព្រឹទ្ធសភា និងការត្រៀមជាបណ្តើរៗ ការរៀបចំជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារការិយាល័យធ្វើការ រួមទាំង

បំពាក់សម្ភារៈ:

-ត្រៀមជួសជុលឡើងវិញអគារស្នាក់នៅរបស់អង្គភាពសន្តិសុខ ឃ្លាំង និងរបងក្រោយអគារE

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ព្រមទាំងការចូលរួមវគ្គផ្សេងៗ រៀបចំដោយសភានៃប្រទេសជាមិត្ត (ឥណ្ឌា...)

-ត្រៀមរៀបចំផលិតវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ត្រៀមរៀបចំសៀវភៅទិនានុលេខន៍ព្រឹទ្ធសភាឆ្នាំ២០២៣។

## IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែកញ្ញានេះ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌ និងពិធីបុណ្យភ្ជុំបិណ្ឌ តាមប្រពៃណី និងគន្លងព្រះពុទ្ធសាសនាយ៉ាងសស្រាក់សស្រាំជាមួយប្រជាពលរដ្ឋ នៅតាមវត្តអារាមនានាទូទាំងប្រទេស។ ស្របពេលជាមួយគ្នានេះដែរ អគ្គលេខាធិការដ្ឋាន នៅតែបន្តការងារយ៉ាងសកម្មក្នុងការផ្តល់សេវាលើមុខងារស្នូលទាំងបីជូនសមាជិកព្រឹទ្ធសភា ក្នុងការបំពេញមុខងាររបស់ខ្លួនបានល្អគាប់ប្រសើរ។ សកម្មភាពលេចធ្លោគឺការផ្តល់សេវាលើមុខងារសហប្រតិការអន្តរជាតិជូនសម្តេចប្រធានបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ដោយបានរៀបចំ និងចាត់ចែងកម្មវិធីជូនសារតាំងរបស់បណ្តាឯកអគ្គរដ្ឋទូតនានាចំនួន០៤លើក ព្រមទាំងការចូលរួមកិច្ចប្រជុំអន្តរជាតិនានាជាពិសេសកិច្ចប្រជុំគណៈកម្មាធិការអេចិន្ត្រៃយ៍នៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង (ASGPF) នៅព្រះរាជាណាចក្រម៉ារ៉ុក ទទួលបានលទ្ធផលជាផ្លែផ្កា។

ក្រៅពីការងាររបស់ស្ថាប័ន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តែងតែយកចិត្តទុកដាក់ និងរួមចំណែកការងារមនុស្សធម៌ និងការងារសង្គមកិច្ចជាប្រចាំ ជាពិសេសការងារជួយសង្គ្រោះអាយុជីវិតប្រជាជន ដោយបានសហការជាមួយមជ្ឈមណ្ឌលជាតិផ្តល់ឈាម រៀបចំកម្មវិធីសប្បុរសធម៌

បរិច្ចាគឈាម ដោយមានការចូលរួមស្ម័គ្រចិត្តពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាច្រើនផងដែរ។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលបានដាក់ចេញ ជាពិសេសវិធានការ "៣ការពារ ៣កុំ" និងការចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីការពារមិនឱ្យជំងឺកូវីដ-១៩ អាចឆ្លងរាលដាលជាថ្មីទៀតបាន។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

**អគ្គលេខាធិការ**

**អ៊ុំ សារឹទ្ធ**